# សេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី៖
# សេចក្តីថ្លែងការណ៍ទីក្រុងស៊ីដនី

ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៨

1. យើង ជាប្រមុខរដ្ឋ/រដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងអូស្ត្រាលី បានជួបជុំគ្នានៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ ដែលជាកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី លើកទី១ នៅប្រទេសអូស្ត្រាលី។
2. យើងទទួលស្គាល់ថា កិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី ឆ្លុះបញ្ចាំងនូវសករាជថ្មីមួយនៃទំនាក់ទំនងអាស៊ាន-អូស្ត្រាលីកាន់តែជិតស្និទ្ធ ដែលត្រូវបានតម្លើងទៅជាភាពជាដៃគូយុទ្ធសាស្ត្រ នៅឆ្នាំ២០១៤។ កិច្ចប្រជុំកំពូលនេះ ជាការអះអាងសារជាថ្មីថា យើងជាដៃគូដ៏សំខាន់ និងរឹងមាំក្នុងតំបន់មួយដែលកំពុងទទួលនូវមានការផ្លាស់ប្តូរសំខាន់ៗជាច្រើន។ យើងប្តេជ្ញាពង្រឹងនូវការងាររបស់យើង ដើម្បីរួមចំណែកសម្រេចបាននូវតំបន់មួយប្រកបដោយសុខសុវត្ថិភាព និងវិបុលភាពសម្រាប់ប្រជាជនរបស់យើង។
3. យើងអះអាងសារជាថ្មីអំពីការប្តេជ្ញាចិត្តរបស់យើង ចំពោះតួនាទីស្នូលរបស់អាស៊ាននៅក្នុងការវិវត្តនៃនិម្មាបនកម្មតំបន់ ដោយឈរលើមូលដ្ឋានច្បាប់ មានលក្ខណៈបើកចំហ តម្លាភាព និងបរិយាប័ន្ន និងលើកកម្ពស់នូវស្ថិរភាព និងវិបុលភាព តាមរយៈយន្តការនាំមុខរបស់អាស៊ាន។ យើងទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់អាស៊ាននៅតែរឹងមាំ ឯកភាព និងនិរន្តរភាព ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងកំណើនជាបរិយាប័ន្ន ព្រមទាំងការរួមចំណែករបស់អាស៊ានជាង៥០ឆ្នាំមកនេះ ឆ្ពោះទៅរកតំបន់មួយប្រកបដោយសន្តិភាព និងវិបុលភាព។ យើងកោតសរសើរនូវការចូលរួមចំណែករបស់អូស្ត្រាលីចំពោះការកសាងសហគមន៍អាស៊ាន ដូចជាការគាំទ្រការអនុវត្តនូវអាស៊ាន២០២៥៖ **វឌ្ឍនភាពរួមគ្នាឆ្ពោះទៅមុខ**។
4. យើងប្តេជ្ញាចិត្តចូលរួមយ៉ាងមុតមាំចំពោះសន្តិភាព និងសន្តិសុខតំបន់ ព្រមទាំងការដោះស្រាយជម្លោះដោយសន្តិវិធី រួមមានការគោរពទាំងស្រុងនូវដំណើរការច្បាប់និងការទូត ការប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ មិនគំរាមកំហែង ឬប្រើប្រាស់នូវកម្លាំង ស្របតាមគោលការណ៍ទទួលស្គាល់ជាសកលនៃច្បាប់អន្តរជាតិ និងសណ្តាប់ធ្នាប់តំបន់ និងអន្តរជាតិ ដោយផ្អែកលើច្បាប់។ យើងទទួលស្គាល់នូវតួនាទីសំខាន់នៃស្ថាប័នតំបន់ និងពហុតំបន់នានា ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការសន្តិភាព និងវិបុលភាព។
5. យើងអះអាងសារជាថ្មីនូវការគោរពគ្នាទៅវិញទៅមកនៃគោលការណ៍អធិបតេយ្យភាព បូរណភាពទឹកដី សមភាព ការមិនជ្រៀតជ្រែក និងឯករាជ្យភាពផ្នែកនយោបាយនៃរដ្ឋទាំងអស់ ដូចដែលមាន

ចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ីអាគ្នេយ៍។ គោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមកការទទួលខុសត្រូវរួម ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលជាចំណុចស្នូល ដើម្បីពង្រឹងថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រ។

## សន្តិសុខតំបន់របស់យើង

6. យើងថ្កោលទោសយ៉ាងមុតមាំ ចំពោះអំពើភេរវកម្ម គ្រប់ទម្រង់ និងរូបភាពទាំងអស់។ យើងបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើងធ្វើការជាមួយគ្នាឱ្យកាន់តែស្អិតរមួតថែមទៀត ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់ប្រយុទ្ធប្រឆាំងអំពើភេរវកម្ម រួមមានទប់ស្កាត់ និងបង្ក្រាបលំហូរភេរវករបរទេសចូលក្នុងតំបន់ និងដោះស្រាយនូវកត្តាជាមូលដ្ឋាន និងលក្ខខណ្ឌនានា ដែលរួមចំណែកដល់ការកើនឡើង និងការរីកសាយភាយនៃអំពើហិង្សាជ្រុលនិយម និងរ៉ាឌីកាលនិយម។ អនុស្សារណៈយោគយល់គ្នារវាងអាស៊ាននិងអូស្ត្រាលី ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើភេរវកម្មអន្តរជាតិ បានចុះហត្ថលេខានៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ ដែលនឹងធ្វើឲ្យកាន់តែស៊ីជម្រៅ និងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការដែលមានស្រាប់យ៉ាងរឹងមាំ។
7. យើងសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការរីករាលដាលនៃភាពតានតឹងនៅក្នុងឧបទ្វីបកូរ៉េ រួមមានបញ្ហាអាវុធនុយក្លេអ៊ែរ និងកម្មវិធីកាំជ្រួចមីស៊ីលរបស់កូរ៉េខាងជើង ដែលបានគំរាមគំហែងដល់សន្តិភាព និងសន្តិសុខក្នុងតំបន់ និងពិភពលោក។ យើងទទូចយ៉ាងខ្លាំងក្លាឱ្យកូរ៉េខាងជើងគោរពជាបន្ទាន់ និងពេញលេញនូវកាតព្វកិច្ចរបស់ខ្លួន ចំពោះសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (អ.ស.ប) និងអំពាវនាវឱ្យប្រទេសសមាជិកអ.ស.ប ទាំងអស់អនុវត្តឱ្យបានពេញលេញនូវសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាសន្តិសុខអ.ស.ប។ យើងបញ្ជាក់សារជាថ្មីនូវការគាំទ្រចំពោះការលុបបំបាត់នូវអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េឱ្យបានទាំងស្រុង ត្រឹមត្រូវ និងគ្មានការវិលត្រលប់មកវិញ ដោយសន្តិវិធី ព្រមទាំងចំពោះគំនិតផ្តួចផ្តើមនានាសំដៅកសាងសន្តិភាពនៅក្នុងឧបទ្វីបកូរ៉េ។ យើងស្វាគមន៍នូវកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងកូរ៉េទាំងពីរ។ យើងក៏សូមស្វាគមន៍នូវការត្រៀមខ្លួនរួចជាស្រេចរបស់អាស៊ាន ក្នុងការដើរតួនាទីស្ថាបនាដ៏សកម្ម ដើម្បីរួមចំណែកដល់សន្តិភាព ស្ថិរភាព នៅឧបទ្វីបកូរ៉េ។
8. ដោយផ្អែកលើផលប្រយោជន៍តាមលំហសមុទ្រ យើងអះអាងនូវទស្សនៈរួមចំពោះសារសំខាន់នៃការប្រើប្រាស់ផ្លូវសមុទ្រ និងមហាសមុទ្រដោយសន្តិវិធី ដែលចាំបាច់ចំពោះសុខមាលភាពសេដ្ឋកិច្ចរបស់យើង។
9. យើងអះអាងសារជាថ្មីអំពីសារសំខាន់នៃការថែរក្សា និងលើកកម្ពស់សន្តិភាព ស្ថិរភាព សុវត្ថិភាព និងសន្តិសុខលំហសមុទ្រ សេរីភាពនៃការធ្វើនាវាចរ និងការហោះហើរនៅក្នុងតំបន់។ យើងសង្កត់

ធូន់អំពីសារសំខាន់នៃការមិនធ្វើយោធូបនីយកម្ម និងភាពចាំបាច់នៃការលើកកម្ពស់ទំនុកចិត្តគ្នាទៅវិញទៅមក ការប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ក្នុងការធ្វើសកម្មភាពនានា និងជៀសវាងនូវសកម្មភាពទាំងឡាយណា ដែលអាចធ្វើឱ្យសភាពការណ៍ស្មុគស្មាញ។ យើងអះអាងសារជាថ្មីអំពីភាពចាំបាច់សម្រាប់វដ្ឋនានា ដើម្បីស្វែងរកនូវដំណោះស្រាយជម្លោះដោយសន្តិវិធី ស្របតាមគោលការណ៍ទទួលស្គាល់ជាសកលនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអ.ស.ប ស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២ និងអនុលោមទៅតាមស្តង់ដារពាក់ព័ន្ធ និងការអនុវត្តជាអនុសាសន៍ ដោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) និងអង្គការលំហសមុទ្រអន្តរជាតិ (IMO)។ ក្នុងន័យនេះ យើងគាំទ្រការអនុវត្តនៃសេចក្តីថ្លែងការណ៍ ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង ឲ្យបានពេញលេញ និងមានប្រសិទ្ធភាពទាំងស្រុង ហើយរង់ចាំការបញ្ចប់នូវក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង ដែលប្រកបដោយប្រសិទ្ធភាព ក្នុងពេលឆាប់ៗនេះ។

10. យើងនឹងបន្តលើកកម្ពស់ថែមទៀតនូវកិច្ចខំប្រឹងប្រែងរបស់យើង ដើម្បីដោះស្រាយនូវបញ្ហាលំហសមុទ្រ ដែលជាបញ្ហាស្មុគស្មាញ ដូចជា សន្តិសុខស្បៀងអាហារ និងជីវភាពរស់នៅ ចោរកម្មសមុទ្រ ការប្លន់ប្រដាប់អាវុធប្រឆាំងនឹងនាវា និងឧក្រិដ្ឋកម្មនានានៅដែនសមុទ្រ ជាមួយនឹងការពង្រឹងសមត្ថភាព និងសុវត្ថិភាពស្រាវជ្រាវរកនាវា ព្រមទាំងតាមរយៈការបន្តការអនុវត្តនៃសេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលអាស៊ីបូ៉ា ស្តីពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់លហសមុទ្រ ដែលមានបំណងក្នុងការបង្កើតនូវតំបន់ដែលមានសុវត្ថិភាព និងស្ថិរភាព ដែលបានផ្តល់នូវបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងវិបុលភាព។

11. យើងនឹងប្តេជ្ញាចិត្តជាថ្មីម្តងទៀត ចំពោះការពង្រឹងនូវកិច្ចសហប្រតិបត្តិការយូរអង្វែងស្តីពីការអនុវត្តច្បាប់/គយ និងអន្តោប្រវេសន៍ ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់ រួមមានការជួញដូរគ្រឿងញៀន ការជួញដូរអាវុធខុសច្បាប់ ការជួញដូរសត្វព្រៃនិងឈើខុសច្បាប់ ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត។ យើងអះអាងឡើងវិញនូវការប្តេជ្ញាចិត្តដើម្បីពង្រីកកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស និងការលើកកម្ពស់សុវត្ថិភាព ទេសន្តប្រវេសន៍អោយបានត្រឹមត្រូវ និងស្របច្បាប់។

12. ពង្រឹងសន្តិភាព និងសន្តិសុខនៅក្នុងតំបន់ យើងប្តេជ្ញាចិត្តលើកកម្ពស់ និងពង្រីកទំហំនិងគុណភាពនៃកិច្ចសហប្រតិបត្តិកិច្ចការគាំពារ ទាំងយន្តការទ្វេភាគី និងពហុភាគី រួមមានវេទិកាតំបន់អាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានការពារជាតិបូក។

**វិបុលភាពនាពេលអនាគតរបស់យើង**

13. ដោយសារទិសដៅសេដ្ឋកិច្ចពាណិជ្ជកម្មកម្រិតខ្ពស់ យើងអះអាងនូវការគាំទ្ររបស់យើងដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងវិនិយោគ ក៏ដូចជាការប្រឆាំងនឹងគ្រប់ទម្រង់នៃការគាំពារនិយម ដើម្បីពង្រឹង

ការអភិវឌ្ឍតំបន់ និងវិបុលភាព។ យើងបានប្តេជ្ញាចិត្តបើកចំហទីផ្សារសេរី និងយកចិត្តទុកដាក់លើប្រព័ន្ធពាណិជ្ជកម្មពហុភាគីដោយផ្អែកលើច្បាប់ជាមូលដ្ឋានសំខាន់។ យើងនឹងបង្កើនកិច្ចខំប្រឹងប្រែងដើម្បីការធ្វើសមាហរណកម្ម និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-អូស្ត្រាលីកាន់តែស៊ីជម្រៅ រួមមាន ការចែករំលែកនូវជំនាញបច្ចេកទេស និងវិធានការកសាងសមត្ថភាពនានា ការពង្រឹងនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការក្របខណ្ឌអនុតំបន់ ដែលជាឧបករណ៍ដើម្បីជំរុញការអភិវឌ្ឍ និងការអនុវត្តនៃកិច្ចព្រមព្រៀងអាស៊ាននានា ពង្រឹងការចូលរួមក្នុងការចរចាពាណិជ្ជកម្មតំបន់ ការពិនិត្យឡើងវិញដោយប្រសិទ្ធភាពចំពោះវិធានការបំបាត់ពន្ធគយ ដែលបង្កើតនូវឧបសគ្គមិនចាំបាច់នានាសម្រាប់វិស័យពាណិជ្ជកម្ម ស្របតាមកិច្ចព្រមព្រៀង បង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដោយការបង្កើនសន្ទុះកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន បរិយាកាសប្រកួតប្រជែងធុរកិច្ច ការបង្កើតការងារ នវានុវត្តន៍ និងសហគ្រិនភាពក្នុងការគាំទ្រសហគមន៍សេដ្ឋកិច្ចអាស៊ាន។

14. ដោយបច្ចេកវិទ្យាប្រព័ន្ធអ៊ីនធើណេត កំពុងក្លាយជាកត្តាស្នូលមួយក្នុងការជំរុញសេដ្ឋកិច្ច យើងសូមប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការ ស្តីពីបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធើណេត និងពាណិជ្ជកម្មឌីជីថល។ យើងបានមានការប្តេជ្ញាចិត្តរួមគ្នាលើកកម្ពស់បរិស្ថានបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដែលមានលក្ខណៈបើកចំហ សុវត្ថិភាព ស្ថិរភាព ដែលអាចទៅដល់ និងដោយសន្តិវិធី ស្របទៅនឹងច្បាប់បទបញ្ញត្តិក្នុងស្រុកនៃប្រទេសនីមួយៗ។ យើងអះអាងនូវការប្តេជ្ញាចិត្តរបស់យើងលើកស្ទួយស្ថិរភាពអន្តរជាតិសម្រាប់លំហប្រព័ន្ធអ៊ីនធើណេត ស្របតាមច្បាប់អន្តរជាតិដែលមានស្រាប់កិច្ច-សហប្រតិបត្តិការកសាងសមត្ថភាព វិធានការកសាងទំនុកចិត្តជាក់ស្តែង បទដ្ឋានឥរិយាបទទទួលខុសត្រូវ ដែលមានលក្ខណៈស្ម័គ្រចិត្ត និងមិនមានចំណងផ្លូវច្បាប់ ផ្អែកលើមូលដ្ឋាននៃរបាយការណ៍ឆ្នាំ២០១៥ របស់ក្រុមអ្នកជំនាញផ្នែករដ្ឋាភិបាលរបស់អ.ស.ប ស្តីពីការអភិវឌ្ឍក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ក្នុងបរិបទនៃសន្តិសុខអន្តរជាតិ។ យើងនឹងលើកកម្ពស់ផងដែរនូវកំណើនសេដ្ឋកិច្ច និងវិបុលភាពប្រកបទៅដោយចីរភាព និងបរិយាប័ន្ន ដូចជាការគាំទ្រពាណិជ្ជកម្មឌីជីថល សហគ្រិនភាព ជួយកសាងនូវពលកម្មការងារលើវិស័យឌីជីថល ដែលមានត្រៀមរួចជាស្រេច និងលើកកម្ពស់ការធ្វើសមាហរ-ណកម្មយើងបន្ថែមទៀតចូលក្នុងទីផ្សារពិភពលោក។

15. យើងទទួលស្គាល់តួនាទីដ៏សំខាន់នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយគុណភាព ចីរភាព និងតម្លាភាព សម្របសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងផែនការនគររូបនីយកម្ម វៃឆ្លាត និងប្រកបដោយចីរភាព នៅក្នុងទីក្រុងដែលកំពុងរីកលូតលាស់របស់យើង ដើម្បីលើកកម្ពស់វឌ្ឍនភាពសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មនៅក្នុងតំបន់របស់យើង។ អាស៊ានស្វាគមន៍ការបន្តគាំទ្ររបស់អូស្ត្រាលី សម្រាប់របៀបវារៈនេះ តាមរយៈការអនុវត្តផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន ឆ្នាំ២០២៥។

16. យើងគាំទ្រវិស័យឯកជនរបស់យើង ដើម្បីពង្រឹងទំនាក់ទំនងធុរកិច្ច តាមរយៈការលើកកម្ពស់កិច្ចសន្ទនារវាងសភាធុរកិច្ចអាស៊ាន-អូស្ត្រាលី អង្គភាពឧស្សាហកម្មកំពូល និងអ្នកតាក់តែងគោលនយោបាយ។ យើងនឹងបន្តកែលម្អលទ្ធផលសម្រាប់ធុរកិច្ច ដូចជាវិធានការ ដើម្បីលើកកម្ពស់លំហូរពាណិជ្ជកម្ម និងវិនិយោគក្នុងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ និងធ្វើឱ្យស៊ីជម្រៅនូវសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ យើងនឹងពង្រឹងនវានុវត្តន៍ និងលើកកម្ពស់ការប្រកួតប្រជែង បរិយាប័ន្នហិរញ្ញវត្ថុ និងសហគ្រិនភាព។ ការផ្តោតដ៏សំខាន់មួយនឹងធ្វើឱ្យសម្រេចនូវសហគ្រាស មីក្រូ តូច និងមធ្យម ដើម្បីផ្តល់ប្រយោជន៍ពីការផ្លាស់ប្តូរផ្នែកឌីជីថល និងធ្វើសមាហរណកម្មបន្ថែមទៀតក្នុងខ្សែសង្វាក់តម្លៃក្នុងតំបន់។

17. យើងប្តេជ្ញាបង្កើនការខិតខំប្រឹងប្រែងក្នុងឆ្នាំ២០១៨ ឆ្ពោះទៅការបញ្ចប់ឱ្យបានឆាប់នូវភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ ដែលមានគុណភាពខ្ពស់ ទូលំទូលាយ និងទំនើប។

18. យើងនឹងជំរុញសេដ្ឋកិច្ចបើកចំហ ថាមវន្ត និងប្រជួតប្រជែង ដែលផ្តល់ផលប្រយោជន៍រួមដល់ប្រជាជន និងលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រី។ យើងនឹងធ្វើការរួមគ្នាដើម្បីធានាឱ្យបានថា ពាណិជ្ជកម្ម និងវិនិយោគ នឹងលើកកម្ពស់ដល់វឌ្ឍនភាពប្រកបដោយចីរភាព និងបរិយាប័ន្ន។ អាស៊ានស្វាគមន៍ការបន្តគាំទ្ររបស់អូស្ត្រាលី ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ក្នុងប្រទេសអាស៊ាន តាមរយៈគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។ យើងអះអាងសារជាថ្មីផងដែរនូវការប្តេជ្ញាចិត្តរួម ដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងស្វាគមន៍ការខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ភាពបំពេញឱ្យគ្នារវាងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងរបៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០ របស់អ.ស.ប។

19. យើងនឹងសហការគ្នាដើម្បីអភិរក្ស និងប្រើប្រាស់ធនធានសមុទ្រប្រកបដោយចីរភាព ដោយអនុលោមតាមច្បាប់អន្តរជាតិ ជាពិសេសអនុសញ្ញាអ.ស.ប ស្តីពីច្បាប់សមុទ្រ និងដោះស្រាយរាល់ការគំរាមកំហែងដល់ធនធានទាំងនេះ រួមទាំង ការនេសាទខុសច្បាប់ គ្មានការរាយការណ៍ និងគ្មានការត្រួតពិនិត្យតាមផ្លូវច្បាប់។

## ប្រជាជនរបស់យើង

20. អាស៊ាន និងអូស្ត្រាលី ចែករំលែកនូវទំនាក់ទំនងវប្បធម៌ សង្គមជាថាមវន្តដ៏យូរអង្វែង និងស៊ីជម្រៅ។ យើងប្តេជ្ញាចិត្តពង្រឹងទំនាក់ទំនងប្រជាជននិងប្រជាជន ជាមួយការផ្តោតជាពិសេសលើការវិនិយោគក្នុងចំណងទំនាក់ទំនងដ៏បិតបេរនាពេលអនាគតរវាងថ្នាក់ដឹកនាំ។ យើងស្វាគមន៍ការរួមចំណែកនៃផែនការកូឡំបូថ្មី ក្នុងការបង្កើតទំនាក់ទំនងយុវជន និងប្តេជ្ញាចិត្តធ្វើឱ្យស៊ីជម្រៅនូវការអប់រំប្រកបដោយជោគជ័យខ្ពស់ និងកម្មវិធីផ្លាស់ប្តូរកីឡា រួមមាន ពានរង្វាន់អូស្ត្រាលី អាហារូបករណ៍ និងកម្មវិធីផ្សេងៗ នៅក្រោមក្រុមប្រឹក្សាអូស្ត្រាលី-អាស៊ាន។

21. យើងប្តេជ្ញាចិត្តចំពោះការលើកកម្ពស់តម្លៃរួម ដូចជា សន្តិភាព សុខដុមរមនា ការយល់ដឹងអន្តរវប្បធម៌ នីតិរដ្ឋ អភិបាលកិច្ចល្អ ការគោរព ទំនុកចិត្ត ការអត់ឱន បរិយាប័ន្ន ការនិយមកណ្តាល ទំនួលខុសត្រូវសង្គម និងភាពចម្រុះគ្នា។

22. យើងចែករំលែកការប្តេជ្ញាចិត្តលើកកម្ពស់ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ក្នុងតំបន់របស់យើង ដើម្បីសម្រេចឱ្យបាននូវសន្តិភាពបរិយាប័ន្ន និងប្រកបដោយចីរភាព និងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងលុបចោលនូវរបាំងនានា ដែលរារាំងដល់ការចូលរួមពេញលេញរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ យើងក៏ប្តេជ្ញាចិត្តផងដែរចំពោះគោលការណ៍របស់ស្ត្រី របៀបវារៈសន្តិភាព និងសន្តិសុខ និងដើម្បីពង្រឹងការសហការស្តីពីការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការកសាង និងធ្វើឲ្យមានសន្តិភាពយូរអង្វែង។ ការធ្វើបរិយាប័ន្ននៃស្ត្រីក្នុងគ្រប់វិស័យទាំងអស់នៃសន្តិភាព និងសន្តិសុខ ជួយដល់ការទប់ស្កាត់ជម្លោះ ធានាបាននូវសន្តិភាពយូរអង្វែង និងគាំទ្រដល់ការស្តារឡើងវិញនៃសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច។

23. យើងចាប់ផ្តើមឡើងវិញនូវការតាំងចិត្តដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៃប្រជាជនរបស់យើង តាមរយៈការងារនៃគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ។ យើងនឹងបន្តលើកកម្ពស់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការ ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ដូចបានកំណត់នៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតូបករណ៍ សិទ្ធិមនុស្សអន្តរជាតិ ពាក់ព័ន្ធផ្សេងទៀត ដែលយើងទាំងអស់ជាភាគី។

24. យើងនឹងបន្តពង្រឹងតំបន់របស់យើងអោយកាន់តែរឹងមាំ ដោយធ្វើកិច្ចសហប្រតិបត្តិការលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងរួមទាំងការដាក់ផែនការ រួមបញ្ចូលទាំងការគាំទ្រនូវមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់ជំនួយមនុស្សធម៌ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ យើងនឹងធ្វើការរួមគ្នា ប្រយុទ្ធប្រឆាំងនឹងជម្ងឺឆ្លង និងរាតត្បាត ដោះស្រាយបញ្ហាប្រឈមសុខភាពដែលកើនឡើង រួមបញ្ចូលនូវបញ្ហាវ័យចាស់ ព្រមទាំងលើកកម្ពស់ការត្រៀមទប់ស្កាត់នឹងជម្ងឺរាតត្បាត តាមរយៈការគាំទ្រប្រព័ន្ធការពារតាមដាន និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។

25. យើងគាំទ្រសកម្មភាពនានា ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ជាពិសេសការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាព និងពេញលេញនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងទិសដៅ និងគោលដៅពាក់ព័ន្ធ នៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ យើងនឹងបន្តលើកស្ទួយការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងព្រៃឈើដោយចីរភាព ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងថាមពលជំនួស និងបច្ចេកវិទ្យាព័ណ៌បៃតង ការគ្រប់គ្រងប្រកបដោយចីរភាពនៃបរិស្ថានឆ្នេរ និងសមុទ្រ និងការអភិរក្ស និងការគ្រប់គ្រងជីវៈចម្រុះ។ យើងនឹងពង្រឹងកិច្ចសហប្រតិបត្តិការ

ក្នុងវេទិកាតំបន់ និងអន្តរជាតិ រួមបញ្ចូលទាំង កិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមការងារអាស៊ាន ស្តីពីការប្រែប្រួលអាកាសធាតុ និងមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន។

26. យើងគាំទ្រវាល់កិច្ចខំប្រឹងប្រែងរបស់អាស៊ាន ក្នុងការអនុវត្តកុងសង់ស៊ីស ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ក្នុងអាស៊ាន។

**កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការអនាគត**

27. យើងប្តេជ្ញាចិត្តបន្តកិច្ចសន្ទនានយោបាយក្នុងកម្រិតប្រមុខរដ្ឋ/រដ្ឋាភិបាល ដោយផ្អែកទៅលើកិច្ចសន្ទនាកម្រិតដ៏ទូលំទូលាយរដ្ឋមន្ត្រី និងឧត្តមមន្ត្រី តាមរយៈកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលអាស៊ាន- អូស្ត្រាលី ២ឆ្នាំម្តង នាពេលអនាគតរបស់យើង។ ពង្រឹងនិម្មាបនកម្មសន្តិសុខតំបន់ក្នុងការគាំទ្រសណ្តាប់ធ្នាប់តំបន់ដោយផ្អែកលើច្បាប់ ជាពិសេសកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ជាវេទិកាយុទ្ធសាស្ត្រតំបន់ដឹកនាំដោយប្រមុខដឹកនាំ និងដើម្បីលើកកម្ពស់កិច្ចសហការក្នុងវេទិកាតំបន់ និងអន្តរជាតិ។

28. យើងនឹងបន្តសហការអនុវត្តដោយពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-អូស្ត្រាលី ឆ្នាំ (២០១៥-២០១៩)។

29. យើងស្វាគមន៍គំនិតផ្តួចផ្តើមលើកឡើងនៅក្នុងកិច្ចប្រជុំកំពូលនេះ ដែលគ្របដណ្តប់លើវិស័យនានាដូចជាការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សន្តិសុខតាមប្រព័ន្ធអ៊ិនធើណេត និងពាណិជ្ជកម្មឌីជីថល ការពារជាតិ លំហសមុទ្រ សេដ្ឋកិច្ច នគរូបនីយកម្ម និងហេដ្ឋា-រចនាសម្ព័ន្ធ ការតភ្ជាប់ អប់រំ សុខុមាលភាព និងស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីពង្រឹងភាពជាដៃគូយុទ្ធសាស្ត្ររបស់យើងបន្ថែមទៀត។ យើងរំពឹងទុកកិច្ចពិគ្រោះយោបល់បន្ថែម ក្នុងការអនុវត្តគំនិតផ្តួចផ្តើមទាំងនេះ។

បានអនុម័តនៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨។

* * * * * * *